# វ៉ាក់សាំងជំងឺ COVID-19
# ការព្រួយបារម្ភជាទូទៅ និងការពិត

### ខ្ញុំព្រួយបារម្ភថា...

វ៉ាក់សាំងនឹងធ្វើឲ្យខ្ញុំកើតជំងឺ COVID-19។

### ✔ ការពិត

**អ្នកមិនអាចកើតជំងឺ COVID-19 ដោយសារតែវ៉ាក់សាំងនោះទេ។**

វ៉ាក់សាំងជំងឺ COVID-19 មិនផ្ទុកវីរុសដែលបង្កឲ្យកើតជំងឺ COVID-19 នោះទេ។

---

### ខ្ញុំព្រួយបារម្ភថា...

វ៉ាក់សាំងនានាគឺមិនមានសុវត្ថិភាព និងមិនមានប្រសិទ្ធភាព។

### ✔ ការពិត

**វ៉ាក់សាំងជំងឺ COVID-19 គឺមានសុវត្ថិភាព និងប្រសិទ្ធភាព។**

វ៉ាក់សាំងនានាត្រូវបានធ្វើតេស្តទៅលើអ្នកចូលរួមរាប់ម៉ឺននាក់នៅក្នុងការសាកល្បងតាមបែបវេជ្ជសាស្រ្ត។វ៉ាក់សាំងទាំងនោះគឺបំពេញទៅតាមស្តង់ដាវិទ្យាសាស្រ្តដើម្បីសុវត្ថិភាពប្រសិទ្ធភាព និងគុណភាពផលិតកម្ម យ៉ាងហ្មត់ចត់របស់ FDAដែលqចាំបាច់ដើម្បីគាំទ្រការអនុញ្ញាតឲ្យប្រើប្រាស់ក្នុងគ្រាមានអាសន្ន ឬការអនុម័តពេញលេញ។វ៉ាក់សាំងទាំងនោះត្រូវបានគេបញ្ជាក់ថាល្អខ្លាំងណាស់ក្នុងការបង្ការកុំឲ្យមនុស្សធ្លាក់ខ្លួនឈឺដោយសារជំងឺ COVID-19។

---

### ខ្ញុំព្រួយបារម្ភថា...

វ៉ាក់សាំង Johnson & Johnson មានផ្ទុកជាលិការបស់ទារកនៅក្នុងគភ៍។

### ✔ ការពិត

**វ៉ាក់សាំង Jonhson & Johnson មិនផ្ទុកនូវផ្នែកទារកនៅក្នុងគភ៌ ឬកោសិកាទារកនៅក្នុងគភ៌នោះទេ។**

វ៉ាក់សាំងនេះត្រូវបានផលិតឡើងដោយប្រើប្រាស់បច្ចេកវិទ្យាដូចគ្នានឹងបច្ចេកវិទ្យាដែលត្រូវបានប្រើប្រាស់ដើម្បីផលិតវ៉ាក់សាំងជាច្រើនផ្សេងទៀតដែរ។ចំណែកមួយនៃវ៉ាក់សាំងនេះត្រូវបានបង្កើតឡើងនៅក្នុងការចម្លងកោសិកាដែលបណ្តុះនៅក្នុងមន្ទីរពិសោធន៍ដែលមានប្រភពដើមមកពីការរំលូតកោសិកាតាមការជ្រើសរើស ដែលបានកើតឡើងជាង 35 ឆ្នាំមុន។ បន្ទាប់ពីពេលនោះមក ការបណ្តុះកោសិកាសម្រាប់វ៉ាក់សាំងទាំងនេះត្រូវបានរក្សាទុកនៅក្នុងមន្ទីរពិសោធន៍។មិនមានប្រភពកោសិកាទារកនៅក្នុងគភ៌បន្ថែមទៀតត្រូវបានប្រើប្រាស់ដើម្បីបង្កើតវ៉ាក់សាំងទាំងនេះទេ។ ព័ត៌មាននេះអាចនឹងជាព័ត៌មានថ្មីសម្រាប់មនុស្សមួយចំនួន។ ប៉ុន្តែ វ៉ាក់សាំងជំងឺអុតស្វាយ រូបេឡា និងជំងឺថ្លើមប្រភេទ A ក៏ត្រូវបានបង្កើតឡើងក្នុងរបៀបដូចគ្នានេះផងដែរ។

---

### ខ្ញុំព្រួយបារម្ភថា...

វ៉ាក់សាំងជំងឺ COVID-19 បណ្តាលឲ្យមិនអាចមានកូនបាន ឬកើតជំងឺអារ។

### ✔ ការពិត

**វ៉ាក់សាំងមិនពាក់ព័ន្ធជាមួយសរីរាង្គបន្តពូជរបស់អ្នកទេ។**

ការព្រួយបារម្ភរបស់អ្នកជុំវិញសុខភាពបន្តពូជ និងវ៉ាក់សាំងគឺអាចយល់បាន។ នេះជាអ្វីដែលយើងដឹង៖ មិនមានភ័ស្តុតាងវិទ្យាសាស្រ្តដែលបង្ហាញថាវ៉ាក់សាំងបណ្តាលឲ្យមិនអាចមានកូន ឬកើតជំងឺអារនោះទេ។ នៅពេលដែលវ៉ាក់សាំងចូលដល់ក្នុងរាងកាយរបស់អ្នក វានឹងធ្វើការជាមួយប្រព័ន្ធភាពស៊ាំរបស់អ្នកដើម្បីបង្កើតអង្គបដិបក្ខប្រាណ ដើម្បីប្រយុទ្ធប្រឆាំងនឹងវីរុសកូរ៉ូណា។ ដំណើរការនេះពុំធ្លាប់បានដឹងថាមានប៉ះពាល់ដល់សរីរាង្គបន្តពូជរបស់អ្នកទេ។

---

**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ COVIDVaccineWA.org ឬទូរសព្ទទៅកាន់លេខ 1-800-525-0127 បន្ទាប់មកចុចសញ្ញា #។ មានជំនួយផ្នែកភាសាសម្រាប់ផ្តល់ជូន។**

Vaccinate WA

CovidVaccineWA.org

ខ្ញុំព្រួយបារម្ភថា...

ខ្ញុំមិនត្រូវការវ៉ាក់សាំងទេ ប្រសិនបើខ្ញុំបានកើតជំងឺ COVID-19 រួចហើយ។

✔ ការពិត

**អ្នកនៅតែគប្បីត្រូវចាក់វ៉ាក់សាំង ប្រសិនបើអ្នកបានកើតជំងឺ COVID-19 រួចហើយ។**

ទិន្នន័យបង្ហាញថា វាមិនមែនជារឿងទូទៅទេដែលនឹងឆ្លងជំងឺ COVID-19 ម្តងទៀតក្នុងរយៈពេល 90ថ្ងៃបន្ទាប់ពីអ្នកបានឆ្លងជំងឺ។ នោះមានន័យថាអ្នកអាចនឹងមានការការពារពីជំងឺ COVID-19 ខ្លះៗហើយ (ដែលហៅថាភាពស៊ាំធម្មជាតិ) សម្រាប់រយៈពេលខ្លី។ ប៉ុន្តែយើងមិនដឹងថាតើភាពស៊ាំពីធម្មជាតិមានរយៈពេលយូរប៉ុនណានោះទេ។

---

ខ្ញុំព្រួយបារម្ភថា...

វ៉ាក់សាំងមានបន្ទះមីក្រូឈីបដែលតាមដានមនុស្ស។

✔ ការពិត

**វ៉ាក់សាំងមិនមានផ្ទុកមីក្រូឈីប ឬឧបករណ៍តាមដាននោះទេ។**

វ៉ាក់សាំងមានផ្ទុកតែសារធាតុផ្សំសកម្មមួយដែលជួយរាងកាយរបស់អ្នកឲ្យបង្កើតអង្គបដិបក្ខប្រាណដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺ COVID-19 បូកជាមួយនឹងខ្លាញ់ អំបិល និងស្ករ។

---

ខ្ញុំព្រួយបារម្ភថា...

វ៉ាក់សាំងជំងឺ COVID-19 គឺមិនមានសុវត្ថិភាពសម្រាប់អ្នកមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន។

✔ ការពិត

**អ្នកជំនាញវេជ្ជសាស្ត្រផ្នែកគភ៌ និងកំណើត បានណែនាំអ្នកដែលមានផ្ទៃពោះ បំបៅដោះកូន ឬមានផែនការមានផ្ទៃពោះ ឲ្យទទួលវ៉ាក់សាំងជំងឺ COVID-19 ។**

ទិន្នន័យបង្ហាញថាវ៉ាក់សាំងជំងឺ COVID-19 គឺមានសុវត្ថិភាពអំឡុងពេលមានផ្ទៃពោះ។ តាមការពិត ការសិក្សាមួយចំនួនបង្ហាញថាម្តាយដែលបានចាក់វ៉ាក់សាំងរួចថែមទាំងអាចបញ្ជូនអង្គបដិបក្ខប្រាណប្រឆាំងនឹងជំងឺ COVID-19 ទៅកាន់កូនរបស់ពួកគេបានតាមរយៈការមានផ្ទៃពោះ និងការបំបៅដោះកូន ថែមទៀតផង។ អ្នកដែលមានផ្ទៃពោះគឺមានហានិភ័យប្រឈមនឹងជំងឺធ្ងន់ធ្ងរដោយសារ COVID-19 រួមទាំងការស្លាប់ផងដែរ។ វ៉ាក់សាំងគឺជាការការពារប្រសើរបំផុត។

---

ខ្ញុំព្រួយបារម្ភថា...

វ៉ាក់សាំងជំងឺ COVID-19 នឹងកែប្រែ DNA របស់ខ្ញុំ។

✔ ការពិត

**វ៉ាក់សាំងជំងឺ COVID-19 មិនកែប្រែ ឬប៉ះពាល់ដល់ DNA របស់អ្នកទេ។**

វ៉ាក់សាំងទាំងអស់ដែលមានសម្រាប់ផ្តល់ជូន គឺធ្វើការបញ្ជូនការណែនាំទៅកាន់កោសិការបស់យើងឲ្យចាប់ផ្តើមបង្កើតការការពារប្រឆាំងនឹងវីរុសដែលបង្កឲ្យកើតជំងឺ COVID-19 ។ វ៉ាក់សាំងមិនចូលទៅក្នុងផ្នែកនៃកោសិកាដែលដាក់ន្លែងផ្ទុក DNA របស់យើងនោះទេ។ ផ្ទុយមកវិញ វ៉ាក់សាំងធ្វើការជាមួយប្រព័ន្ធការពារពីធម្មជាតិនៃរាងកាយរបស់យើងដើម្បីបង្កើតប្រព័ន្ធភាពស៊ាំ។

---

ខ្ញុំព្រួយបារម្ភថា...

ខ្ញុំនឹងជួបប្រទះអាការៈកកឈាមបន្ទាប់ពីចាក់វ៉ាក់សាំងរួច។

✔ ការពិត

**ហានិភ័យនៃការកកឈាមគឺមានអត្រាទាបខ្លាំងណាស់។**

ឧទាហរណ៍ ហានិភ័យគឺទាបជាងឆ្ងាយណាស់ បើប្រៀបធៀបនឹងហានិភ័យដែលអាចមានបញ្ហាឈាមកកដោយសារការពន្យារកំណើត ដែលស្ត្រីរាប់លាននាក់ធ្វើការពន្យារកំណើតជារៀងរាល់ថ្ងៃ។ Washington State Department of Health (DOH, ក្រសួងសុខាភិបាល) នៃរដ្ឋវ៉ាស៊ីនតោនណែនាំឱ្យអ្នកចាក់វ៉ាក់សាំងជំងឺ COVID-19 ស៊េរី mRNA (Pfizer-BioNTech ឬ Moderna) ជំនួសវ៉ាក់សាំង Johnson & Johnson (J&J) ដោយសារតែហានិភ័យដែលអាចកើតមាន។

វ៉ាក់សាំង J&J នៅតែអាចប្រើបាន ប្រសិនបើអ្នកមិនអាច ឬមិនចង់ចាក់វ៉ាក់សាំងស៊េរី mRNA ទេ។ សូមពិភាក្សាជាមួយអ្នកផ្តល់ការថែទាំសុខភាពអំពីហានិភ័យរបស់អ្នក។



ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនគថ្លង់ ឬពិបាកក្នុងការស្តាប់ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬអ៊ីម៉ែល civil.rights@doh.wa.gov